# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរទន្លេសាប**

លេខ : ២៥០.......អទស

ថ្ងៃ សុក្រ ៥កើត ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ២០២៥

**ជម្រាបជូន**

**- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង**

**- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់**

**- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង**

**- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ**

**- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តសៀមរាប**

**- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ**

**កម្មវត្ថុ ៖** សំណើចាត់វិធានការការពារ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពនៃការរុករាន កាប់ឆ្ការ និងដុតឈូសឆាយទន្រ្ទានយកដីព្រៃលិចទឹក និងដីមិនបានធ្វើការកាត់ឆ្វៀលនៅក្នុងដែនដីតំបន់ទ្រនាប់នៃដែនព្រៃលិចទឹក (តំបន់២) ក្នុងភូមិសាស្រ្តខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប។

**យោង ៖**
- អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្រ្តី នៃ **ព្រះរាជាណាចក្រកម្ពុជា**
- ច្បាប់ ស្តីពីជលផល
- ច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ក្រមបរិស្ថាន និងធនធានធម្មជាតិ
- អនុក្រឹត្យលេខ:៨៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល
- លិខិតលេខ:១៨៥៧ សជណ.កបច ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្រ្តី។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងឯកសារយោងខាងលើ សូមជម្រាបជូន **ឯកឧត្តមអភិបាល** ជ្រាបថា៖ ក្នុងស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវលើការចុះតាមដានត្រួតពិនិត្យ និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកជាប្រចាំ ក្នុងភូមិសាស្រ្តខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប អាជ្ញាធរទន្លេសាប បានពិនិត្យឃើញសកម្មភាពអនាធិបតេយ្យ នៃការឈូសឆាយទន្រ្ទានទីតាំងតំបន់ដីមានព្រៃលិចទឹក និងការចាប់យកដីព្រៃលិចទឹកដែលមិនបានធ្វើការកាត់ឆ្វៀល ដើម្បីជីក ឬស្តារអាងទឹក ប្រឡាយទឹក និងប្រើប្រាស់អាស្រ័យផល រួមជាមួយការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ដូចជា អាងទឹក ទំនប់ទឹក ជីកប្រឡាយ ផ្លូវ និងសំណង់ផ្សេងៗ ក្នុងនោះក៏មានការចាក់លុបស្រះ ត្រពាំង និងប្រឡាយទឹកធម្មជាតិ ស្ថិតនៅក្នុងដែនដីតំបន់ទ្រនាប់នៃដែនព្រៃលិចទឹក (តំបន់២) ដោយមិនបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នជំនាញ ដែលផ្ទុយទៅនឹងច្បាប់បទដ្ឋានគតិយុត្តបានកំណត់ ជាហេតុបង្កផលប៉ះពាល់ជាអវិជ្ជមានដល់សក្តានុពលធនធានធម្មជាតិដ៏កម្រ សុខមាលភាពបឹង និងលំនឹងប្រព័ន្ធអេកូឡូស៊ីរបស់បឹងទន្លេសាបទាំងមូល រួមមាន ការបាត់បង់ជម្រកពងកូន បម្រែបម្រួលគម្របដី ការហូរច្រោះល្បាប់កក់បង្កការគោករាក់បឹង ខូចគុណភាពទឹក ប៉ះពាល់របបជលសាស្រ្ត។ល។

អគារលេខ: ៣៦៤.មហាវិថី ព្រះមុនីវង្ស,សង្កាត់ ផ្សារដើមថ្កូវ,ខណ្ឌ ចំការមន,រាជធានីភ្នំពេញ, ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២៣ ៧២៧ ៤៥៤
# 364 Monivong Blvd., Phsar Deumthkov, Khan Chamkarmorn, Phnom Penh, Cambodia. Phone/Fax: (855) 23 727 454, Website: www.tonlesap.gov.kh

ក្នុងនាមជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាល លើការសម្របសម្រួល ដឹកនាំគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប អាជ្ញាធរទន្លេសាប ស្នើឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ) ចូលរួមអនុវត្តដោយម៉ឺងម៉ាត់ ក្នុងការចាត់វិធានការការពារ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពនៃការរុករាន កាប់ឆ្ការ និងដុតឈូសឆាយទន្ទ្រានយកដីព្រៃលិចទឹក និងដីមិនបានធ្វើការកាត់ឆ្វៀលនៅក្នុងដែនដីតំបន់ទ្រនាប់ នៃដែនព្រៃលិចទឹក (តំបន់២) ក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប ឬត្រូវស្នើសុំការអនុញ្ញាតមកក្រសួង ស្ថាប័នជំនាញ (ក្រសួងធនធានទឹក និងឧតុនិយម និងអាជ្ញាធរទន្លេសាប) ពិនិត្យលក្ខណៈបច្ចេកទេសឲ្យបានត្រឹមត្រូវជាមុន ដើម្បីជៀសវាងផលប៉ះពាល់ធ្ងន់ធ្ងរដល់ធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិរបស់បឹងទន្លេសាប ជាធនធានធម្មជាតិដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ដែលត្រូវគ្រប់គ្រង ថែរក្សា ការពារ ទុកជាកេរមរតក សម្រាប់កូនចៅជំនាន់ក្រោយៗ។

អាជ្ញាធរទន្លេសាប នៅតែបន្តសហការជាមួយក្រុមការងារអន្តរក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ក្នុងការចុះពិនិត្យ តាមដាន និងអធិការកិច្ចរាល់សកម្មភាពបទល្មើស ដែលកើតមានឡើងនៅក្នុងតំបន់បឹងទន្លេសាប និងធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមអភិបាល ពិនិត្យ និងមានវិធានការចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព តាមការគួរ។

សូម ឯកឧត្តមអភិបាល ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

ប្រធាន

ចៅ_ជេដ្ឋា

**<u>ចម្លងជូន ៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងធនធានទឹក និងឧតុនិយម
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងបរិស្ថាន
-អង្គភាពប្រឆាំងអំពើពុករលួយ
-ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
"ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ